**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំនព្វមាស ឆ្នាំ២០១៨ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងនព្វមាស ឆ្នាំ២០១៨នេះ តាមការកត់សម្គាល់ឃើញថា ស្ថានភាពរបាយទឹកភ្លៀងមានភាពមិនស្មើគ្នានៅតាមតំបន់មួយចំនួននៃរាជធានី-ខេត្ត ជាហេតុបណ្តាលឱ្យតំបន់ខ្លះរងផលប៉ះពាល់ដោយទឹកជំនន់ និងតំបន់ខ្លះទៀតខ្វះទឹក ដែលធ្វើឱ្យមានការខូចខាតដំណាំរដូវវស្សា។ ការងារបង្កបង្កើនផលស្រូវរដូវវស្សាសម្រេចបានចំនួន ២ ៧២៨ ០៧៩ហ.ត ស្មើនឹង១០៨,៥២% នៃផែនការ ២ ៥១៣ ៨៩៥ហ.ត។ ការប្រើប្រាស់គ្រឿងយន្តសម្រាប់ការរៀបចំដីផលិតកម្មដំណាំ-ស្រូវគឺស្មើនឹង៩៦,៤២% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របីមាន៣,៥៨% រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល ក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងនព្វមាស ឆ្នាំ២០១៨នេះគឺ ការរៀបចំកិច្ចប្រជុំសំខាន់ៗ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងនព្វមាស ឆ្នាំ២០១៨នេះ មានដូចតទៅៈ

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះរដូវវស្សាឆ្នាំ២០១៨

#### ១.១ ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាគិតត្រឹមថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៨ មានលម្អិតដូចខាងក្រោមៈ

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៩៤២ ៤៥០ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ១០៥ ៤២៣ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៨៣៧ ០២៧ហ.ត លើសឆ្នាំមុនចំនួន ៥០ ៥០៨ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ៣២ ៥២៤ហ.ត តិចជាងឆ្នាំមុនចំនួន ៩ ៣៨៧ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៧២៨ ០៧៩ហ.ត ស្មើនឹង ១០៨,៥២% នៃផែនការ ២ ៥១៣ ៨៩៥ហ.ត លើសឆ្នាំមុនចំនួន ១១៨ ៤៦២ហ.ត។

#### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវវស្សាឆ្នាំ២០១៨

-ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន ៤៦ ៨១២ហ.ត ស្មើនឹង ៩៦,០៦% នៃផែនការ ៤៨ ៧៣១ហ.ត តិចជាងឆ្នាំមុនចំនួន ២ ២២១ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៨៦៨ ១៣៤ហ.ត ស្មើនឹង ១០៥,៧១% នៃផែនការ ៨២១ ២១៧ហ.ត លើសឆ្នាំមុនចំនួន ៤៧ ៨៥៥ហ.ត។

#### ១.៣ ស្ថានភាពផលប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ

-ការខ្វះខាតទឹកប៉ះពាល់ដំណាំស្រូវចំនួន ១៨៥ ៤៣៦ហ.ត និងដំណាំរួមផ្សំចំនួន ៤ ៣៥៥ហ.ត ដោយស្តារបានឡើងវិញចំនួន ៩ ៨៥៨ហ.ត

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia.
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

-គ្រោះធម្មជាតិពីទឹកភ្លៀង និងទឹកជំនន់ទន្លេមេគង្គប៉ះពាល់លើរាជធានី-ខេត្តចំនួន ២២ដោយខូចខាតទាំងស្រុងចំនួន ៥៤ ០៤៣ហ.ត និងស្តារឡើងវិញបានចំនួន ៦ ៣៧១ហ.ត។

### ១.៤ ការនាំចេញអង្ករ

ក្នុងខែកញ្ញា ឆ្នាំ២០១៨នេះ ការនាំអង្ករចេញតាមរយៈច្រកចេញ-ចូលតែមួយគឺមានបរិមាណសរុបចំនួន ៤៧ ៦២៦តោន ដែលមានការថយចុះចំនួន ២ ១៥០តោន (-៤,៥០%) ធៀបនឹងបរិមាណនាំចេញក្នុងខែកញ្ញា ឆ្នាំ២០១៧។ សរុបរយៈពេល ៩ខែ ឆ្នាំ២០១៨ នាំចេញបានចំនួន ៣៨៩ ២៦៤តោន ការនាំចេញទៅកាន់ទិសដៅចំនួន ៥៩ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ (៩៦ ៧១៤តោន) ប្រទេសបារាំងឈរលំដាប់ទី២ (៥៧ ៦៧៦តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៣ (២៨ ០៦៧តោន) ប្រទេសហូឡង់ឈរលំដាប់ទី៤ (២១ ៥០០តោន) ប្រទេសប៉ូឡូញឈរលំដាប់ទី៥ (១៩ ៩៤៧តោន) ប្រទេសណេដឺឡែនឈរលំដាប់ទី៦ (១៩ ០៥៨តោន) ប្រទេសអង់គ្លេសឈរលំដាប់លេខទី៧ (១៤ ៧៩០តោន) ប្រទេសប៊ែលហ្ស៊ិកឈរលំដាប់ទី៨ (១៣ ៩៨១តោន) ហុងកុងឈរលំដាប់ទី៩ (១១ ៨០៨តោន) និងប្រទេសអ៊ីតាលីឈរលំដាប់ទី១០ (១១ ១៧៤តោន)។ បច្ចុប្បន្នការនាំចេញអង្ករមានចំនួន ៧៣ក្រុមហ៊ុន។ ទន្ទឹមនឹងនោះ អង្ករក្រអូបប្រណិតកម្ពុជាបានឈ្នះពានរង្វាន់ជាអង្ករល្អជាងគេបំផុតក្នុងពិភពលោកសម្រាប់ឆ្នាំ២០១៨ នៅក្នុងសន្និសីទស្រូវអង្ករពិភពលោកលើកទី១០ (10th World Rice Conference) នៅទីក្រុងហាណូយ ប្រទេសវៀតណាម។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| លរ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហត) | ផលិតផលអនុវត្តបានប្រចាំ៩ខែ (តោន) | បញ្ចេញលក់ប្រចាំ៩ខែ (តោន) |
|---|---|---|---|---|---|
| I.ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៦៧០ | ៨០១ | ៣៧២ | ៤០០ |
| សរុប I | | ៦៧០ | ៨០១ | ៣៧២ | ៤០០ |
| II. ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុនសុភក្តិនិកា អ៊ីនវេសមេនគ្រុប | ១២ ៤០៤ | ១៥ ២៧៣ | ១១ ១២៥ | ១២ ៧៤៨ |
| ២ | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | ១ ១៩១ | ២ ០៤៧ | ១ ០៧៣ | ១ ០២៩ |
| ៣ | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៥៦៥៨ | ៨ ១៥៣ | ២៨៩៩ | ៣២២០ |
| ៤ | ក្រុមហ៊ុន ស៊ីហ្សាប់ប៊ើលីមីធីត (រតនគីរី) | ៧៩ | ២ ៦៦៦ | ៨ ០ | 0 |
| ៥ | ក្រុមហ៊ុនស៊ីហ្សវីសសស់(ស្នួល) | ៣ ៨៥៩ | ៤ ៤០៦ | ២ ៩១២ | ៣ ៣៧២ |
| ៦ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ៣៤៣ | ៤ ១៨៧ | ៣ ៣៤៧ | ៣ ២៥៣ |
| ៧ | ក្រុមហ៊ុន អានម៉ារ៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣ ៣២៧ | ៥ ៩២៤ | ១ ៨៥៧ | ១ ៨២៣ |
| ៨ | ក្រុមហ៊ុនអានម៉ារ៉ាឌីគ្រុប (ពាមជាំង របាស់ហែក) | ១ ៨៨២ | ៣ ១២៤ | ៩៧៣ | ៩៧៧ |
| ៩ | ក្រុមហ៊ុនក្រេក(ខេមបូឌា)ខូអិលធីឌី | ៤ ៣៥៩ | ៤ ៧៩៨ | ៣ ៩៣៣ | ៣ ៧៤៤ |
| សរុបII | | ៣៦ ១០១ | ៥១ ៣៨០ | ២៨ ២០០ | ៣០ ៤៣៧ |
| III. ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៤៥ ៣២៣ | ២២០ ៥០៦ | ៣០ ៧០២ | ២៩ ៣៦៦ |
| ១២ | ក្រុមហ៊ុនចម្ការកៅស៊ូគ្រួសារ | ១១៩ ៨៣៧ | ១៥៦ ១១២ | ៨០ ២០០ | ៨០ ១០០ |
| សរុប III | | ១៦៥ ១៦០ | ៣៧៦ ៦១៨ | ១១០ ៩០២ | ១០៩ ៤៦៦ |
| សរុប I + II + III | | ២០១ ៩៣១ | ៤២៧ ៩៩៨ | ១៣៩ ៤៧៤ | ១៤០ ៣០៣ |

គួរកត់សម្គាល់ថាតម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងខែកញ្ញា ឆ្នាំ២០១៨នេះគឺ ១ ២៦៣ដុល្លារ/តោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានចូលរួមប្រជុំពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងវិសោធនកម្មព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- ចូលរួមជាមួយគណៈប្រតិភូជប៉ុន និងជំនាញការ CIRAD និងCATAS ចុះត្រួតពិនិត្យការងារស្រាវជ្រាវកៅស៊ូនៅស្ថានីយអនុវត្តខេត្តត្បូងឃ្មុំ
- បានចុះពិនិត្យក្រុមហ៊ុនចម្ការកៅស៊ូនៅខេត្តមណ្ឌលគិរីដើម្បីពិភាក្សា និងរៀបចំបើកមុខចៀរឡូត៍ពិសោធន៍
- វិភាគបរិមាណជ័រស្ងួត DRC លើចម្ការពិសោធន៍នីមួយៗតាមវិធីសាស្ត្រដុត និងតាមមន្ទីរពិសោធន៍
- រៀបចំដីនិងបោះបង្គោលតម្រុយសម្រាប់ការដាំដុះកៅស៊ូឆ្នាំ២០១៨ នៅប្លុក៤២BN លើផ្ទៃដី១២,៥ហ.ត
- បានបំប៉ៅកូនកៅស៊ូចំនួន ៤២ក្លូននៅថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០១៧-២០១៨
- ធ្វើតេស្តវិភាគសំណាកយថាប្រភេទចំនួន ១០៧សំណាក សម្រាប់ពិនិត្យគុណភាពរបស់រោងចក្រកែច្នៃកៅស៊ូនៃគម្រោង AFD
- ចុះត្រួតពិនិត្យ និងប្រមូលទិន្នន័យគ្រប់ឡូត៍ពិសោធន៍ក្លូននៅចម្ការកៅស៊ូជប់ និងក្រែក
- បានត្រួតពិនិត្យតាមដានការលាបថ្នាំរំញោច Ethephon គ្រប់ចម្ការពិសោធន៍ទាំងអស់
- បានវិភាគសរីសាស្ត្រទឹកជ័រ LD ចំនួន ៩ចម្ការពិសោធន៍គឺ AA01 AA02 AA07 AA09 SSCT01 IRAE03 IRAE06 IRAE08 IRAE09 ស្មើនឹង៣៣២សំណាក
- ដាំជួសកូនកៅស៊ូលើចម្ការដាំឆ្នាំ២០១៨ នៅប្លុក៥២CS លើក្លូន IRCA230 និងប្លុក៤២BNW លើក្លូន GT។

## ៣ ផ្នែកកសិ-ឧស្សាហកម្ម

- បានរៀបចំសិក្ខាសាលាស្តីពី វិធីសាស្ត្រ និងបច្ចេកវិទ្យាថ្មីនៃការគ្រប់គ្រងបៃតងសម្រាប់អភិវឌ្ឍន៍កសិកម្ម ដោយសហការជាមួយវិទ្យាស្ថានការពាររុក្ខជាតិនៃបណ្ឌិតសភាវិទ្យាសាស្ត្រកសិកម្មចិន
- បានសហការជាមួយវិទ្យាស្ថានចិនស្រាវជ្រាវលើឧស្សាហកម្មអាហារ និងអាហារឡើងមេ
- បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការត្រួតពិនិត្យ និងគ្រប់គ្រងកាកសំណល់ថ្នាំពុលកសិកម្មនៅក្នុងផលិតផលកសិកម្ម
- បានចូលរួមជួបភ្ញៀវស្ថានទូតអាមេរិច និងសហការី
- បានចុះបណ្តុះបណ្តាលកសិករអំពី ស្តង់ដារ គុណភាព និងសុវត្ថិភាពនៃផលិតផលកសិកម្មចំនួន ៥គោលដៅ
- បានចុះបណ្តុះបណ្តាលកសិករអំពីបច្ចេកទេសកែច្នៃបន្លែ ផ្លែឈើ និងគ្រាប់ធញ្ញជាតិចំនួន ៥គោលដៅ
- បានចូលរួមកម្មវិធីបើកពិព័រណ៍ផ្សារណាត់បន្លែសុវត្ថិភាព និងផលិតផលសុវត្ថិភាពរបស់គម្រោងជំរុញផលិតកម្មស្បៀង
- បានចូលរួមកិច្ចប្រជុំលើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នារវាងអាស៊ាន និងប្រទេសចិនស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម និងស្បៀង
- បានចូលរួមកិច្ចប្រជុំលើសេចក្តីព្រាងស្តីពីវិសោធនកម្មកិច្ចព្រមព្រៀង APTERR
- បានចូលរួមសន្និសីទជាតិលើកទីមួយលើភាពស៊ាំ និងឱសថប្រឆាំងមេរោគនៅកម្ពុជា
- បានចូលរួមពិភាក្សាលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតក្រុមការងារចុះសិក្សាលទ្ធផលអាចធ្វើបានលើគម្រោងបង្កើតតំបន់កសិកម្មចម្រុះ។

## ៤ ផ្នែកផលិតកម្ម និងបសុពេទ្យាបាល

**៤.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្ត និងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្ទូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការបន្តជាមួយគម្រោង EU-PGA-L។

**៤.២ ការងារបសុពេទ្យាបាល**

- លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖ ក្នុង១ខែមាស ឆ្នាំ២០១៨នេះ រាជធានី-ខេត្តចំនួន២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៣១ ៨១៩លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តទូទាំងប្រទេសចំនួន ៦ករណី បាន

កម្ទេចចោលផលិតផលខូចគុណភាពតាមវិធានបសុពេទ្យសរុបចំនួន ១៦៨គ.ក្រ និងផាកពិន័យជាទឹកប្រាក់ ព្រមទាំងបានណែនាំដល់អាជីវករដែលដឹកជញ្ជូនសត្វរស់ឲ្យប្រតិបត្តិជីវសុវត្ថិភាពពេញលេញដើម្បីការពារការឆ្លងរាលដាលនៃជំងឺផ្សេងៗ។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យជាប្រចាំលើទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង«ខ» តាមបណ្តារាជធានី-ខេត្ត និងចុះវាយតម្លៃការងារសត្តឃាតដ្ឋានចំនួន ១៨ខេត្ត។
- **ការងារនីតិកម្មនិងវិវាទ៖**

- ចុះផ្សព្វផ្សាយច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វនៅរាជធានី-ខេត្តចំនួន១៧

- បានសម្រេចប្រកាសស្តីពីនីតិវិធី និងការតម្រូវបមាណីការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម និងប្រកាសស្តីពីនីតិវិធី និងការតម្រូវបមាណីការចុះបញ្ជីឱសថ សារធាតុសកម្ម ឬសមាសធាតុ

- បានកំពុងកែសម្រួលសៀវភៅបច្ចេកទេសចិញ្ចឹមជ្រូក និងគោ

- ចុះពង្រឹងនិងអនុវត្តប្រកាសលេខ០៥១ប្រ.កសក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ស្តីពី ដល់ក្រុមហ៊ុនផលិតចំណីសត្វចំនួន ៩ខេត្ត។

### ៤.៣ ការងារស្រាវជ្រាវ

- **ការងារស្រាវជ្រាវបសុព្យាបាលៈ** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៦ ៨២៣វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ និងបានរកឃើញមេរោគជំងឺផ្តាសាយបក្សីផ្ទុះ ៧ករណីនៅរាជធានីភ្នំពេញ ខេត្តមណ្ឌលគិរី កណ្តាល ព្រៃវែង សៀមរាប ត្បូងឃ្មុំ ។
- **ការងារស្រាវជ្រាវផលិតកម្មៈ** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៤ក្បាល ក្នុងនោះគោប្រាម៉ាន់កាត់ ៣៣ក្បាល គោបៅដោះ ៣៤ក្បាល គោកំផែងសែន ៣៧ក្បាល។ ដោយឡែក នៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ២៧៥ក្បាល។

**៤.៤ ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចុះផ្សព្វផ្សាយជំងឺឆ្លងសត្វនៅខេត្តចំនួន ១៧ដោយរៀបចំសិក្ខាសាលាស្តីពីការកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមសត្វ។

## ៥ ផ្នែកព្រៃឈើ

### ៥.១ ការងារព្រៃឈើ

- បញ្ចប់ការទាញយករូបភាពផ្កាយរណប (Landsat8) សម្រាប់ធ្វើការបកស្រាយគម្របព្រៃឈើឆ្នាំ២០១៨ និងកំពុងបកស្រាយចំណាត់ថ្នាក់ប្រភេទព្រៃឈើនីមួយៗបានចំនួន ៩០%

- ចេញប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៣០កន្លែង មានផ្ទៃដីព្រៃសរុបទំហំ ៣៥ ៥៧៣,៦៦ហ.ត

- បានចុះបើកវគ្គផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងការគ្រប់គ្រង និងការអនុវត្តលិខិតបទដ្ឋានច្បាប់ពាក់ព័ន្ធនឹងសហគមន៍ព្រៃឈើ ផលប្រយោជន៍ព្រៃសហគមន៍ និងនិតិវិធីទប់ស្កាត់បទល្មើសព្រៃសហគមន៍ចំនួន ២២វគ្គដល់សហគមន៍ព្រៃឈើចំនួន ២២នៅក្នុងខេត្តចំនួន ១១រួមមាន៖ ខេត្តកំពត កែប កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង ស្ទឹងត្រែង កំពង់ធំ សៀមរាប ឧត្តរមានជ័យ និងខេត្តក្រចេះ

- ចុះតាមដាន និងត្រួតពិនិត្យការងារសហគមន៍ព្រៃឈើចំនួន ៥៤កន្លែង ក្នុងខេត្តចំនួន ០៩រួមមាន៖ ខេត្តរតនគិរី ស្ទឹងត្រែង សៀមរាប ក្រចេះ ព្រះវិហារ កំពង់ធំ បន្ទាយមានជ័យ កំពត និងខេត្តបាត់ដំបង។

### ៥.២ ការងារអភិរក្សសត្វព្រៃ

- បានសហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋានចុះអន្តរាគមន៍ទប់ស្កាត់ និងបង្ក្រាបការជួញដូរសត្វព្រៃចំនួន ០៨លើក នៅខេត្តក្រចេះ ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី ព្រះសីហនុ ពោធិ៍សាត់ និងព្រះវិហារ ដោយបាន ចាប់ឃាត់សាច់ជ្រូកព្រៃ និងសាច់ឈ្លូសចំនួន ៣១គ.ក្រ ដកហូតរណារយន្តចំនួន ០១គ្រឿង ដោះអន្ទាក់សត្វចំនួន ១៥៩ខ្សែ រឹបអូសសត្វត្រកួតរស់បានចំនួន ០៨ក្បាល អណ្តើកចំនួន ០១ក្បាល ព្រមទាំងបានលែងសត្វទាំងនេះចូលក្នុងព្រៃធម្មជាតិ និងធ្វើកិច្ចសន្យាបញ្ឈប់ការកាប់រានដីព្រៃបានចំនួន ០១ករណី

- ចុះសិក្សាស្រាវជ្រាវ និងធ្វើការតាមដានវត្តមានសត្វព្រៃចំនួន ០៧លើក នៅខេត្តស្ទឹងត្រែង បាត់ដំបងព្រះវិហារ សៀមរាប ពោធិ៍សាត់ និងកោះកុង បានកត់ត្រានូវប្រភេទសត្វព្រៃសំខាន់ៗចំនួន ១៣៦ប្រភេទ រួមមាន៖ ថនិកសត្វចំនួន ៣៦ប្រភេទ សត្វស្លាបចំនួន ៧៩ប្រភេទ និងឧរង្គសត្វចំនួន ២១ប្រភេទ

- សហការជាមួយអង្គការ WWF និងធ្វើកិច្ចសន្យាជាមួយសហគមន៍មូលដ្ឋានដើម្បីការពារ និងយាមសម្បុកសត្វស្លាបនៅតាមតំបន់ព្រៃលិចទឹកទន្លេមេគង្គស្ថិតនៅក្នុងស្រុកសៀមបូក ខេត្តស្ទឹងត្រែង និងស្រុកសំបូរ ខេត្តក្រចេះ

ដែលមានសម្បុកសត្វស្លាប (ត្រដក់តូច ត្រយ៉ងចង្កំកស រំពេទន្លេ ត្មាតផេះ ត្មាតភ្លើង) ចំនួន ១១៨សម្បុក ដែលកូនអាច ហើរបានមានចំនួន ២០៨ក្បាល។

### ៥.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន ០៦ ដែលមានកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ០៧ ទីតាំង ស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងកំពង់ឆ្នាំងមានស្វាក្តាមសរុបចំនួន ៥៥ ៩៧៩ក្បាល ក្នុងនោះកូនកើតរយៈពេល០៩ខែសរុបចំនួន ៩ ២៨៣ក្បាល ដឹកជញ្ជូនក្នុងស្រុកបានចំនួន ១ ៦២១ក្បាល និងនាំចេញទៅក្រៅប្រទេសបានចំនួន ៧ ០៤២ក្បាល

- ចុះធ្វើជំរឿនសត្វស្វានៅតាមទីសាធារណៈ និងតំបន់សួនសត្វនៅរាជធានីភ្នំពេញ ខេត្តកណ្តាល តាកែវ កំពង់ស្ពឺ កំពង់ចាម ក្រចេះ កំពង់ធំ បាត់ដំបង និងខេត្តព្រះសីហនុ ដោយបានរាប់ឃើញសត្វស្វាសរុបចំនួន ២ ៩៧០ ក្បាល ក្នុងនោះមានសត្វស្វាក្តាមចំនួន ២ ៧៤៣ក្បាល សត្វស្វាត្រោសចំនួន ២២៦ក្បាល និងសត្វស្វាព្រាមចំនួន ០១ ក្បាល

- សម្រាប់នព្វមាស ឆ្នាំ២០១៨ នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៥៤៣ក្បាល (បក្សីចំនួន ៥៥ ប្រភេទ ថនិកសត្វចំនួន ៤១ ប្រភេទ និងល្មូនចំនួន ១២ ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១ ០៨៧ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ១៧៧ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ៧៧០ក្បាល។ ដោយឡែក គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ៖ ក្រុមល្បាតសហគមន៍ចំនួន ៣០នាក់ បានដើរល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥រួមមាន នៅអារ៉ែង ឆាយរ៉ាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)។

### ៥.៤ ការងារដាំដើមឈើ

- បានស្នើសុំចុះបញ្ជីដីរដ្ឋនូវដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ០៧ទីតាំង មានផ្ទៃដីសរុប ៤៧ ៦៨៣,៣១ហ.ត

- បាននិងកំពុងអនុវត្តគម្រោងដាំឈើចម្ការថ្មីទំហំ ១៥២ហ.ត នៅស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ២ ទីតាំងរួមមាន៖ ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំចំនួន ៦៥ហ.ត និងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើអូរថ្ម ខេត្តព្រះសីហនុចំនួន ៨៧ហ.ត

- បាននិងកំពុងបន្តថែទាំចម្ការឈើចាស់ ចម្ការពូជឈើ ឡូតិ៍បង្ហាញកសិ-រុក្ខកម្មនៅទីតាំងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើចំនួន ៣ទីតាំង ស្ថិតនៅខេត្តសៀមរាប កំពង់ធំ និងខេត្តស្វាយរៀង លើផ្ទៃដីសរុបទំហំ ១ ២០៥ហ.ត

- បានបណ្តុះកូនឈើគ្រប់ប្រភេទចំនួន ៦៣៦ ៩៨៨ដើម ហើយបានប្រគេនកូនឈើដល់ព្រះសង្ឃ ចែកចាយជូនប្រជាពលរដ្ឋ អង្គភាពរដ្ឋ និងសាធារណជនយកទៅដាំចំនួន ២៨៤ ២៤៨ដើម។

### ៥.៥ ការងារនីតិកម្មនិងវិវាទ

- សម្រាប់នព្វមាស ឆ្នាំ២០១៨នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ៨៤៦ ករណី ដោយពិន័យអន្តរការណ៍ចំនួន ៤២២ករណី និងបញ្ជូនទៅតុលាការចំនួន ៤២៤ករណី។ ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់រួមមាន៖ ឈើមូល-ជ្រុងចំនួន ២៥០ម៣ ឈើអារចំនួន ៤ ២១៣ម៣ គ្រាក់គ្រញូងចំនួន ១០ម៣ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន ១ ៣៦៧ក្បាល និង១ ៥៣០គ.ក្រ និងអនុផលព្រៃឈើព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត។

### ៥.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ចុះពិនិត្យដល់ទីតាំងជាក់ស្តែងតាមលក្ខណៈបច្ចេកទេសជូនក្រុមហ៊ុន និងអតិថិជនចំនួន១៧បានស្នើសុំបន្តសុពលភាពរោងម៉ាស៊ីនអារ-កែច្នៃឈើចំនួន១៩កន្លែង និងក្រុមហ៊ុនចំនួន៧ដែលបានស្នើសុំបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន៧កន្លែង ព្រមទាំងបានចុះសិក្សាអត្រាកែច្នៃកូនឈើចំនួន៣ក្រុមហ៊ុន

- ក្រុមហ៊ុនចំនួន១១បានធ្វើការនាំចេញផលិតផលរានទេវតា និងឈើកែច្នៃទៅក្រៅប្រទេសមានបរិមាណសរុប ៣ ៩៩៨ម៣ ចំណាំងកម្ទេចឈើចំនួន៥០០តោន និងជ័រទឹកចំនួន២៩២តោន

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផល-អនុផលព្រៃឈើចំនួន១២ក្រុមហ៊ុនមានបរិមាណឈើកែច្នៃសរុបចំនួន ៥ ៨៣១ម៣ ឈើអាកាស្យា-ប្រេងខ្យល់កាត់ជាកង់ៗចំនួន៨ ២៥០ស្ទែរ និងផលិតផលជ័រទឹកចំនួន២១៦តោន ព្រមទាំងបានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលផល-អនុផលព្រៃឈើចំនួន៦ក្រុមហ៊ុនមានបរិមាណឈើកែច្នៃសរុបចំនួន៤ ៤៧២ម៣។

### ៥.៧ ការងារចំណូលព្រៃឈើ

- សម្រាប់នព្វមាស ឆ្នាំ២០១៨នេះ ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើសរុបចំនួន ១៥ ១៩៧ ២៨៦ ៤៨៦ រៀល និង១១០ ៧៤០,៩២ដុល្លារ។

## ៦ ផ្នែកជលផល

### ៦.១ អាជីវកម្មនេសាទ

#### ៦.១.១ នេសាទទឹកសាប

- ដាយត្រីបានបញ្ចប់ត្រឹមចំនួន ២ ៥៩០តោន ស្មើនឹង២១,៥៨% នៃផែនការ១២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ ថយចុះចំនួន ២ ៣៩៥តោន
- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តបានចំនួន ១៩៧ ៦៨០តោន ស្មើនឹង៥៧,៣០% នៃផែនការ ៣៤៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ កើនឡើងចំនួន ៥ ០៣០តោន
- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ៧៦ ១០០តោន ស្មើនឹង៥២,៤៨% នៃផែនការ ១៤៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ កើនឡើងចំនួន ៥០០តោន។

#### ៦.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ៨៧ ៨៥០តោន ស្មើនឹង៧៩,៨៦% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ កើនឡើងចំនួន ១ ០២៥តោន។

### ៦.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ២០៣ ៤៤៨តោន ស្មើនឹង៨១,៣៨% នៃផែនការ ២៥០ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ កើនឡើងចំនួន ៣៥ ៩៨៥តោន
- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ២៥១ ៧០០ក្បាល ស្មើនឹង៨៣,៩០% នៃផែនការ ៣០០ ០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ កើនឡើងចំនួន ១៣ ៤០០ក្បាល
- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ១៥៧ ៥០០ ០០០កូន ស្មើនឹង៧១,៥៩% នៃផែនការ ២២០ ០០០ ០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ កើនឡើងចំនួនប្រមាណ ៦ ០០០ ០០០កូន។

### ៦.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តបានចំនួន ៤៣ ៤០០តោន ស្មើនឹង៥២,៩៣% នៃផែនការ ៨២ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ កើនឡើងចំនួន ២ ១០០តោន
- ផលនេសាទសមុទ្រអនុវត្តបានចំនួន ៨ ៤៣៥តោន ស្មើនឹង៩៣,៧២% នៃផែនការ ៩ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ កើនឡើងចំនួន ៩៥តោន
- ការផលិតទឹកត្រីអនុវត្តបានចំនួន ៤៥ ៩០០ ០០០លីត្រ ស្មើនឹង៧៦,៥០% នៃផែនការ ៦០ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ កើនឡើងចំនួន ១ ១០០ ០០០លីត្រ។

### ៦.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សម្រាប់នព្វមាស ឆ្នាំ២០១៨នេះ សំណុំរឿងបទល្មើសជលផលមានចំនួន ២ ២៤៨ករណី ប្រៀបធៀបក្នុងឆ្នាំ២០១៧ ថយចុះចំនួន ៦២២ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២ ០៩៥ករណី និងសមុទ្រចំនួន ១៥៣ករណី
- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមានៈ របាំងស្នៃមុងនិងសាច់អួនប្រវែង ៨២៣ ២៧៥ម៉ែត្រ បង្គោល/ចម្រឹងចំនួន ៣៧៥ ៤៣៧ដើម សម្រាស់ទំហំ ៤៩ ៥៥២ម៉ែត្រក្រឡា លូស្នៃមុងនិងសាច់អួនចំនួន ១១ ៧៦៦ មាត់ លបកែច្នៃចំនួន ២ ៧៤៦គ្រឿង ឧបករណ៍ឆក់ត្រីចំនួន ២៨៥គ្រឿង និងលែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន ៤៥ ១២៧គ.ក្រ។

### ៦.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់អនុវត្តបានចំនួន ៧ ០៦០តោន ស្មើនឹង៤៧,០៧% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ កើនឡើងចំនួន ១១០តោន
- ផលនេសាទកែច្នៃអនុវត្តបានចំនួន ៣ ៩៧០តោន ស្មើនឹង៧៩,៤០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦ កើនឡើងចំនួន ៩០តោន។

### ៦.៦ ការប្រមូលថវិកា

- ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលក្នុងនព្វមាស ឆ្នាំ២០១៨ ចំនួន ១ ២៩៩ ៩៥៥ ៥៣២រៀល នៃផែនការ ៣ ០៤៣ ៦០០ ០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៧ ថយចុះចំនួន ១ ២៧៧ ១១៥.៦៥១រៀល។

## ៧ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានបញ្ចេញពូជស្រូវផ្កាមាលតីជាពូជក្រអូបប្រណីតមួយពូជទៀតជូនកសិករប្រើប្រាស់ និងបានប្រមូលសំណាកដំណាំត្រសក់ ម្រះ និងចេកបានចំនួន ២៦សំណាក ព្រមទាំងបានវាយតម្លៃ និងកំណត់លក្ខណៈសំណាកដំណាំម្ទេសបានចំនួន ៩៥សំណាក ត្រសក់ស្រូវបានចំនួន ៦១សំណាក និងល្ពៅបានចំនួន ១៧សំណាក

- បានធ្វើពិសោធន៍និងស្រែបង្ហាញចំនួន ៧៩ប្រភេទ ក្នុងនោះមានពិសោធន៍ចំនួន ១០៧កន្លែងនិងស្រែបង្ហាញចំនួន ៣៧៦កន្លែង អង្កេតចំនួន៧ប្រភេទលើកសិករចំនួន ៣ ៣៩០នាក់។ បានធ្វើទិវាស្រែនិងបើកវគ្គបណ្តុះបណ្តាលកសិករចំនួន២០លើក មានកសិករចូលរួម ៧៦៨នាក់ និងបានចែកគ្រាប់ពូជស្រូវគ្រឹះជូនកសិករចំនួន៤៥៧គ្រួសារមានបរិមាណសរុប ២ ២៨៥គ.ក្រ សម្រាប់ដាំទុកជាគ្រាប់ពូជក្នុងឆ្នាំក្រោយ

- បានបោះពុម្ពឯកសារឡើងវិញចំនួន ២១ ៨០០ច្បាប់ និងបែងចែកឯកសារសរុបចំនួន ៣៤ ៦៦០ច្បាប់ ចំនួនអ្នកប្រើប្រាស់ព័ត៌មានបច្ចេកវិទ្យារបស់វិទ្យាស្ថានកាឌីតាមរយៈគេហទំព័រ http://www.cardi.org.kh មានចំនួនសរុប ៤៧៧ ៧៥៣នាក់។

## ៨ ផ្នែកនីតិកម្មកសិកម្ម

### ៨.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាសម្ភារកសិកម្មបានចំនួន ១៨០ក្រុមហ៊ុន សរុបចំនួន ២៦៦មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលសម្ភារកសិកម្មចំនួន ១៩៩ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៤៩ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៣៨ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតប្រតិបត្តិការលាយផ្សំ ឬវេចខ្ចប់ជាថ្មីថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១២ក្រុមហ៊ុន។

### ៨.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគសារធាតុលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៧២ក្រុមហ៊ុន សរុបចំនួន ៤៧៤សំណាក។

### ៨.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- រៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពី បទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្ម។

## ៩ ផ្នែករដ្ឋបាល

- ក្នុង៧មាស ឆ្នាំ២០១៨នេះ បានទទួលលិខិតពីក្រសួង-ស្ថាប័ននានាចំនួន ២ ៧៣៨ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ២ ៩៨១ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១ ២៩៨ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តបានចំនួន ៩ ៥៣៩ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ៤១៥ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១៩២ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ ដូចជាវុឌ្ឍិទិវា មច្ចុទិវា ចុះសួរសុខទុក្ខកងវរៈសេនាតូចលេខ១ លេខ២ លេខ៣ និងបានចូលរួមទិវាស្បៀងអាហារពិភពលោក។ និងបានចូលរួមរាល់កិច្ចប្រជុំ ដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ១០ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន ៦ ៨២៩នាក់ ក្នុងនោះនារីចំនួន ១ ៦០៧នាក់ ស្មើនឹង ២៣% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៨៨៨នាក់ ក្នុងនោះនារីចំនួន ៨១៣នាក់ ស្មើនឹង ២៨%
  + អង្គភាពថ្នាក់ក្រោមជាតិចំនួន ៣ ៩៤១នាក់ ក្នុងនោះនារីចំនួន ៧៩៤នាក់ ស្មើនឹង ២០%
- ត្រូវបានតែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៧៦នាក់ នារី១៥នាក់
- បានចេញប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន ៣៦នាក់ នារី៥នាក់ ក្នុងនោះ បោះបង់ចោលការងារចំនួន ៩នាក់ សុំលាឈប់ពីការងារចំនួន ៦នាក់ និងមរណភាពចំនួន ២១នាក់

- បានចេញប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងមានចំនួន៨នាក់ ផ្ទេរចូលក្នុងក្រសួងមានចំនួន៨នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងមានចំនួន៤១នាក់

- បានធ្វើលិខិតផ្តល់នីត្យានុកូលភាពជូនមន្ត្រីរាជការបានចំនួន៤១នាក់

- ត្រៀមរៀបចំប្រឡងជ្រើសរើសមន្ត្រីក្របខ័ណ្ឌថ្មី ដែលក្រសួងមុខងារសាធារណៈបែងចែកឲ្យមកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានចំនួន៤០នាក់

- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារមានចំនួន១២០នាក់ នារី៨០នាក់ ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន៥៦នាក់ ច្បាប់ព្យាបាលជំងឺចំនួន១២នាក់ និងច្បាប់លំហែមាតុភាពចំនួន៥២នាក់

- បានចេញប្រកាសដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន៣៩នាក់

- បានចេញប្រកាសដាក់មន្ត្រីឲ្យចូលនិវត្តន៍ និងបាត់បង់សម្បទាវិជ្ជាជីវៈចំនួន១៣៥នាក់

- បានចេញប្រកាសតំឡើងថ្នាក់តាមសញ្ញាបត្រជូនមន្ត្រីរាជការចំនួន៤២៤នាក់

- ការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន២ ០៥៧នាក់ នារី៤៩៧នាក់ ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមចំនួន១ ៥៦១នាក់ នារី៣៤៧នាក់
  + ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន៤៩៦នាក់ នារី១៥០នាក់ ក្នុងនោះ ការបណ្តុះបណ្តាលរយៈពេលខ្លីនិងមធ្យមចំនួន៤៨១នាក់ និងរយៈពេលវែងចំនួន១៥នាក់។

## ១១ មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ដាក់ឲ្យដំណើរការជាផ្លូវការនូវគេហទំព័រថ្មីរបស់ក្រសួងដែលមានអាសយដ្ឋាន www.maff.gov.kh

- បន្តតាមដានលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែលម្អគេហទំព័រអង្គភាពក្រោមឱវាទក្រសួង និងមន្ទីររាជធានី-ខេត្ត និងបានដាក់មុខងារចំនួនអ្នកចូលទស្សនានៅលើគេហទំព័រមន្ទីររាជធានី-ខេត្ត

- ចុះបណ្តុះបណ្តាលអំពីការប្រើប្រាស់ និងគ្រប់គ្រងគេហទំព័រដែលបានបង្កើតរួចរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានីភ្នំពេញ ប៉ៃលិន កែប ព្រះសីហនុ ត្បូងឃ្មុំ កំពត តាកែវ ព្រៃវែង ស្វាយរៀង កំពង់ស្ពឺ និងកោះកុង

- ចុះតាមដាន និងជំរុញការអនុវត្តការប្រើប្រាស់គេហទំព័រតាមមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង បាត់ដំបង កែប កំពត កំពង់ចាម និងខេត្តស្ទឹងត្រែង

- ចុះសហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ បាត់ដំបង ឧត្តរមានជ័យ សៀមរាប និងខេត្តពោធិ៍សាត់ ដោយបញ្ចូលទិន្នន័យទីតាំងពាក់ព័ន្ធនឹងផលិតកម្ម ការប្រមូលទិញ និងការកែច្នៃផលិតផលកសិកម្ម អំពីការប្រើប្រាស់គេហទំព័រព័ត៌មានភូមិសាស្ត្រកសិកម្ម និងធ្វើបទបង្ហាញពីគេហទំព័រព័ត៌មានភូមិសាស្ត្រ វិធីប្រើប្រាស់ និងណែនាំពីកម្មវិធីដែលផ្តល់ភាពងាយស្រួលក្នុងការប្រមូលទិន្នន័យដើម្បីបញ្ចូលក្នុងគេហទំព័រ

- រៀបចំសិក្ខាសាលាស្តីពី "ការប្រើប្រាស់ និងគ្រប់គ្រង Web Admin"

- រៀបចំសិក្ខាសាលាស្តីពី "ការពិនិត្យវឌ្ឍនភាពនៃរបៀបប្រើប្រាស់ និងគ្រប់គ្រងគេហទំព័ររបស់អង្គភាពក្រោម

- រៀបចំសិក្ខាសាលាបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យកសិកម្ម

- រៀបចំសិក្ខាសាលាស្តីពី "មូលដ្ឋាននៃការកសាងផែនទី"

- បានរៀបចំផលិត និងផ្សព្វផ្សាយវីដេអូកសិកម្មស្តីពីការផលិត និងប្រើប្រាស់បន្លែសុវត្ថិភាពនៅខេត្តពោធិ៍សាត់ និងបន្តចុះថតវីដេអូកសិកម្មនៅខេត្តបន្ទាយមានជ័យ។

## ១២ ផ្នែកផែនការនិងស្ថិតិ

- បានសហការ និងសម្របសម្រួលការអនុវត្តគម្រោង EU និងចូលរួមពិភាក្សាសៀវភៅណែនាំស្តីពីការតាមដាន និងវាយតម្លៃ

- បានពិនិត្យផ្តល់យោបល់ និងរៀបចំលិខិតឆ្លើយតបលើការងារស្រូវពូជ

- បានលើកសំណើសុំទៅរាជរដ្ឋាភិបាលដើម្បីជម្រះបំណុលអន្តរ៍គមន៍ និងការបាត់បង់ដោយសារការផ្លាស់ប្តូរស្រូវពូជចាស់ ប្តូរយកស្រូវពូជថ្មីសរុបចំនួន ៣ ៣៣១,០២តោន

- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់សន្និធិស្រូវពូជនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម ស្ទឹងត្រែង និងស្វាយរៀង

- បានតាមដាន និងចុះអនុវត្តការងារផែនការថវិកាតាមកម្មវិធីក្នុងឆ្នាំ២០១៨

- បានពិនិត្យវាយតម្លៃលើការអនុវត្តការងារគម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្នុងខេត្តចំនួន១៩ ដែលមានសម្បទានដីសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៧

- បានរៀបចំសិក្ខាសាលាស្តីពីការប្រមូល និងប្រើប្រាស់ទិន្នន័យស្ថិតិកសិកម្មនៅខេត្តកំពង់ឆ្នាំង

- បានចូលរួមប្រជុំពិគ្រោះយោបល់ស្តីពីការរៀបចំធ្វើអង្កេតចន្លោះជំរឿនកសិកម្មកម្ពុជាឆ្នាំ២០១៩។

## ១៣ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១៣.១ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៧-២០១៨ សរុបមានចំនួន ៣ ១០០នាក់ (ស្រី១ ០៩១នាក់) ចែកចេញជា ១០មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមសម្រាប់ការបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត
- គ្រប់មហាវិទ្យាល័យបានបញ្ចប់កម្មវិធីសិក្សាក្នុងឆមាសរបស់ខ្លួន ហើយបានដឹកនាំនិស្សិតចុះធ្វើកម្មសិក្សានៅតាមសហគមន៍ ក្រុមហ៊ុនឯកជន កសិដ្ឋានកសិកម្ម
- បានរៀបចំពិធីបំពាក់កន្សែងក្រហមជូននិស្សិតក្លឹបកាកបាទក្រហមកម្ពុជាប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្មចំនួន១០០នាក់ និងបានចូលរួមប្រឡងប្រកួតប្រជែងសម្តែងសិល្បៈ ក្នុងមហោស្រពសិល្បៈជាតិទូទាំងប្រទេសឆ្នាំ២០១៨ ទទួលបានចំណាត់ថ្នាក់លេខ២កម្រិតឧត្តមសិក្សា។

### ១៣.២ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៧-២០១៨ សរុបចំនួន ៩១៦នាក់ (ស្ត្រី ៣២៧នាក់) ក្នុងនោះនិស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៦៣៩នាក់(ស្ត្រី ២៣៧នាក់) និងនិស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន ២១៥នាក់(ស្ត្រី ៧៤នាក់) និងបណ្តុះបណ្តាលខ្លីចំនួន ៦២នាក់ (ស្ត្រី ១៦នាក់) លើជំនាញ៖ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរួមបញ្ចូលគោលនយោបាយស្រាវជ្រាវក្នុងការផ្សព្វផ្សាយ និងបណ្តុះបណ្តាលកសិកម្មនៅប្រទេសកូរ៉េ
- បានចុះអនុស្សរណៈយោគយល់គ្នាជាមួយ National Ping tung University of Science ប្រទេសតៃវ៉ាន់
- បានសហការជាមួយ Cambodia-Japan Reserch Center for Agriculture របស់ក្រុមហ៊ុនជប៉ុនចំនួន ៣មកធ្វើបទបង្ហាញដល់និស្សិតស្តីពីដំណាំចេក
- កំពុងរៀបចំគម្រោងពិសោធន៍ និងអភិរក្សសត្វផ្សោតនៅខេត្តក្រចេះដោយសហការជាមួយក្រុមហ៊ុន និងសាកល-វិទ្យាល័យប្រទេសចិន
- បន្តសហការជាមួយ Vitrosys ក្រុមហ៊ុនកូរ៉េ ជំរុញការស្រាវជ្រាវផ្នែកបណ្តុះជាលិកា។

### ១៣.៣ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៧-២០១៨ សរុបមានចំនួន ៥៨៧នាក់ (ស្ត្រី ២៦១នាក់) រួមមាន៖ និស្សិតថ្នាក់បរិញ្ញាបត្រចំនួន ៣៣៩នាក់ (ស្ត្រី ១៧៨នាក់) និស្សិតថ្នាក់បរិញ្ញាបត្ររងចំនួន ១៣៤នាក់ (ស្ត្រី ៥២នាក់) និងនិស្សិតសិក្សាបង់ថ្លៃចំនួន ១១៤នាក់ (ស្ត្រី ៣១នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- បានពិសោធប្រៀបធៀបការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- បានចាប់ផ្តើមពិសោធចិញ្ចឹមដង្កូវនាងព្រៃ និងការបង្កាត់ពូជដង្កូវនាងព្រៃថ្មី
- បានបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងវិភាគបាក់តេរី
- បានរៀបចំពិសោធជីកំប៉ុស្តលើដំណាំស្ពៃក្តោប ស្រូវ និងបន្លែផ្សេងៗ
- បានកំពុងបន្តអនុវត្តគម្រោងធ្វើឱ្យប្រសើរឡើងគុណភាពសិក្សា និងកែលម្អសាលាជាតិកសិកម្មកំពង់ចាមតាមវិធីសាស្ត្រចលនាភូមិថ្មីក្រោមជំនួយ KOICA នៃសាកលវិទ្យាល័យកាំងវុង។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាសម្រេចបានចំនួន ២ ៧២៨ ០៧៩ហ.ត ស្មើនឹង ១០៨,៥២% នៃផែនការ ២ ៥១៣ ៨៩៥ហ.ត។ ជាមួយនឹងការខិតខំដាំដុះដំណាំរដូវវស្សាយ៉ាងសស្រាក់សស្រាំរបស់ប្រជាកសិករ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិត

ចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឲ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្តាញសង្គមផ្សេងៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍវិស័យកសិកម្មក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអន្តរស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែននៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវរដូវវស្សា និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណនិងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៨-២០១៩ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញការអនុវត្តសេចក្តីជូនដំណឹងស្តីពីការបង្ការនិងទប់ស្កាត់ការរាតត្បាតនៃជំងឺម៉ូសាអ៊ិច (ជំងឺស្លឹកពពាល) (CMD) លើដំណាំដំឡូងមីឱ្យកាន់តែខ្លាំងក្លាបន្ថែមទៀត

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំរួមផ្សំផ្សេងទៀតដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ និងកាត់បន្ថយការប្រើប្រាស់សារធាតុគីមី

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផលរដូវវស្សានេះ និងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ដើម្បីពិនិត្យអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការលើកទិសដៅអនុវត្តបន្ត

- បន្តណែនាំដល់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់សហការជាមួយអាជ្ញាធរមូលដ្ឋានចុះធ្វើអន្តរាគមន៍ ដើម្បីស្វែងរកដំណោះស្រាយទប់ស្កាត់ការធ្លាក់ចុះថ្លៃកសិផលផ្សេងៗជាយថាហេតុ ការងារសម្របសម្រួលថ្នាក់តំបន់ និងថ្នាក់ខេត្ត ដើម្បីជួយដោះស្រាយបញ្ហាពាក់ព័ន្ធនឹងការងារស្រាវជ្រាវអង្កេតនៅមូលដ្ឋានក៏ដូចជាទីផ្សារកសិផលផ្សេងៗទៀតផងដែរ

- យកចិត្តទុកដាក់គិតគូរផ្សព្វផ្សាយអំពីការប្រើប្រាស់ជីកសិកម្ម ថ្នាំកសិកម្ម និងសារធាតុគីមីផ្សេងៗទៅលើផលិតផលកសិកម្មដែលនាំឲ្យប៉ះពាល់សុខុមាលភាពសាធារណៈ ការនាំចេញកសិផលទៅក្រៅប្រទេស និងលើកកម្ពស់ផលិតកម្មកសិកម្មសរីរាង្គ

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡត់ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទ និងរោងចក្រកែច្នៃកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ ធ្វើការ

វិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះផងដែរ។

## ២ ផ្នែកផលិតកម្មនិងបសុព្យាបាល

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស ព្រមទាំងជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនបៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- បន្តចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី-ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានការបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- បន្តពង្រឹងកិច្ចសហការក្នុងក្របខ័ណ្ឌត្រួតពិនិត្យអនាម័យសត្វ និងផលិតកម្មសត្វក្នុងក្របខ័ណ្ឌទ្វេភាគី តំបន់ និងអន្តរជាតិ ព្រមទាំងចូលរួមក្នុងការរៀបចំកិច្ចព្រមព្រៀងទទួលស្គាល់ជំនាញបសុព្យាបាលនៅក្នុងក្របខ័ណ្ឌ ASEAN ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មជំនាញបសុព្យាបាលក្នុងចំណោមប្រទេសសមាជិក ASEAN។

## ៣ ផ្នែកព្រៃឈើ

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើជាតិ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយក្រសួង ស្ថាប័ន សមត្ថកិច្ចជំនាញ សហគមន៍ព្រៃឈើ និងភាគីពាក់-ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជាលេខ០១ និង០២ របស់រាជរដ្ឋាភិបាល និងចូលរួមអនុវត្តសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើប្រកបដោយប្រសិទ្ធភាព។

## ៤ ផ្នែកជលផល

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៩ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គាក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរស់ ត្រីឆ្អៅឱ្យបានសមស្របតាមវិធានបច្ចេកទេស

ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ
- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក
- បន្តសកម្មភាពការងារបង្កើតទម្រង់បន្ថែមលើប្រព័ន្ធគេហទំព័រភូមិសាស្ត្រកសិកម្ម និងរៀបចំទម្រង់នៃការបញ្ចូលទិន្នន័យព័ត៌មាន ទីតាំងប្រមូលទិញ ទីតាំងលក់ រោងម៉ាស៊ីនកិនស្រូវ ដែលតម្រូវឱ្យ Admin Page បញ្ចូលព័ត៌មានសំខាន់ៗ
- ធ្វើការកែលម្អសេវាសាធារណៈច្រកចេញចូលតែមួយរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទប្រកបដោយតម្លាភាពនិងទាន់ពេលវេលា ការផ្ទេរមុខងារទៅថ្នាក់ក្រោមជាតិតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ
- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី
- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ ព្រមទាំងការបញ្ចូលសកម្មភាពយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់ៗតាមផ្នែកនីមួយៗផងដែរ
- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក
- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស
- បន្តសហការរៀបចំច្បាប់ផ្សេងៗ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធក្នុងក្របខ័ណ្ឌកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់តាមបែបវិមជ្ឈការនិងវិសហមជ្ឈការនៅតាមអង្គភាពក្រោមឱវាទតាមការចាំបាច់ និងលំដាប់អាទិភាព
- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា ហើយក៏ជាយន្តការមួយ រួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា ពីកសិកម្មបែបរបបប្បកម្មដែលមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលធាតុអាកាស ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។

ថ្ងៃពុធ ១២ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ០៨ ឆ្នាំ២០១៨

**រដ្ឋមន្ត្រីស្តីទី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វុធ_ចាន់សុខា**